Commonwealth of Massachusetts
Executive Office of Energy & Environmental Affairs

Department of Environmental Protection

100 Cambridge Street 9th Floor Boston, MA 02114 • 617-292-5500

Charles D. Baker
Governor

Karyn E. Polito
Lieutenant Governor

Bethany A. Card
Secretary

Martin Suuberg
Commissioner

# កម្មវិធី (Title 5) និងការអនុញ្ញាតទីជម្រាល (Watershed Permitting)៖ បានពិនិត្យឡើងវិញលិខិតជូនដំណឹងអំពីសវនាការសាធារណៈថ្មីដោយមានការបន្ថែមរយៈពេលផ្តល់មតិយោបល់

## លិខិតជូនដំណឹងស្តីពីសវនាការសាធារណៈបានបោះពុម្ពផ្សាយនៅក្នុងបញ្ជីឈ្មោះរដ្ឋម៉ាសាជូសេត Massachusetts ដោយរដ្ឋលេខាធិការរដ្ឋម៉ាសាជូសេត Massachusetts នៅថ្ងៃទី 11 ខែវិច្ឆិកា ឆ្នាំ 2022។ តាមរយៈលិខិតជូនដំណឹងដែលបានពិនិត្យឡើងវិញនេះ MassDEP នឹងផ្តល់ជូនបន្ថែមរយៈពេលផ្តល់មតិយោបល់រហូតដល់ម៉ោង 5 ល្ងាច នៅថ្ងៃទី 30 ខែមករា ឆ្នាំ 2023

លិខិតជូនដំណឹងស្តីពីសវនាការសាធារណៈដែលបានពិនិត្យឡើងដោយមានការបន្ថែមរយៈពេលផ្តល់មតិជាលាយលក្ខណ៍អក្សរមានជាភាសាដែលមានជម្រើស (Español -- Tiếng Việt -- ចិន -- Kreyòl Ayisyen -- Português -- ខ្មែរ) តាមរិបសាយ MassDEP: https://www.mass.gov/service-details/massdep-public-hearings-comment- opportunities

តាមន័យនេះលិខិតជូនដំណឹងត្រូវបានផ្តល់ជូនដោយអនុលោមតាម M.G.L. c. 30A ក្រសួងការពារបរិស្ថាន (MassDEP) នឹងស្នើសុំធ្វើវិសោធនកម្មក្រមបរិស្ថានរដ្ឋ នៃកម្មវិធី Title 5, 310 CMR 15.000, និងផ្សព្វផ្សាយបទប្បញ្ញត្តិថ្មីដែលមានចំណងជើងថាបទប្បញ្ញត្តិការអនុញ្ញាតទីជម្រាលនៅចំណុច 314 CMR 21.00, ដោយអនុលោមតាមការផ្តល់សិទ្ធិអនុញ្ញាតរបស់ខ្លួននៅ M.G.L. c. 21A § 13, G.L. c. 21 § 27, និងផ្នែក 2A នៃជំពូក 259 នៃច្បាប់ឆ្នាំ 2014។ MassDEP នឹងស្នើសុំធ្វើវិសោធនកម្មបទប្បញ្ញត្តិកម្មវិធី Title 5 ដើម្បីបង្កើនការការពារឆ្នេរសមុទ្រនិងមាត់ទន្លេ ជាពិសេសនៅ Cape Cod, កោះ នឹងរដ្ឋម៉ាសាជូសេតភាគខាងត្បូង Southeastern Massachusetts - ពីការបំពុលជាតិអាសូតដែលមានប្រភពចេញពីទឹកកាកសំណល់។ បទប្បញ្ញត្តិដែលបានស្នើឡើងរបស់ MassDEP នៅចំណុច 314 CMR 21.00 ផ្តល់ជូនដំណោះស្រាយការអនុញ្ញាតទីជម្រាលដើម្បីគ្រប់គ្រងអាសូតនិងសារធាតុបំពុលផ្សេងៗទៀតពីការចូលទៅនៅឆ្នេរសមុទ្រនិងមាត់ទន្លេ។ វិសោធនកម្មនិងបទប្បញ្ញត្តិដែលបានស្នើឡើងអាចមាននៅលើគេហទំព័ររបស់ MassDEP៖

https://www.mass.gov/info-details/massdep-public-hearings-comment-opportunities
https://www.mass.gov/regulations/310-CMR-15000-septic-systems-title-5
https://www.mass.gov/regulations/314-CMR-2100-watershed-permit-regulations

### មតិយោបល់សាធារណៈ និងសវនាការ

MassDEP បានធ្វើសវនាការជាសាធារណៈចំនួនបីលើក៖ **ថ្ងៃទី 30 ខែវិច្ឆិកា ឆ្នាំ 2022 វេលាម៉ោង 6:00 ល្ងាច; ថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2022 វេលាម៉ោង 1:00 រសៀល; ថ្ងៃទី 5 ខែ ធ្នូ ឆ្នាំ 2022 វេលាម៉ោង 6:00 ល្ងាច**។ ការថតអាចមាននៅលើបណ្តាញ YouTube និងគេហទំព័រ MassDEP នៅ https://www.mass.gov/regulations/310-CMR-15000-septic-systems-title-5

**ការបន្ថែមរយៈពេលផ្តល់មតិយោបល់ និងសវនាការសាធារណៈបន្ថែម៖**

**រយៈពេលផ្តល់មតិយោបល់ត្រូវបានពន្យារពេលរហូតដល់ម៉ោង 5:00 ល្ងាច នៅថ្ងៃទី 30 ខែមករា ឆ្នាំ 2023។**

**ព័ត៌មាននេះ អាចមានជាទម្រង់ដែលមានជម្រើស។ សូមទាក់ទង Melixza Esenyie តាមលេខ 617-626-1282.**
**TTY# សេវាបញ្ជូនបន្ត MassRelay Service 1-800-439-2370 វិបសាយ MassDEP**
**Website: www.mass.gov/dep**
**ក្រដាសបោះពុម្ពឬកែច្នៃឡើងវិញ។**

**MassDEP នឹងធ្វើសវនាការជាសាធារណៈចំនួនពីរលើក៖**
ពីចម្ងាយតែប៉ុណ្ណោះ នៅថ្ងៃទី 24 ខែមករា ឆ្នាំ 2023 វេលាម៉ោង 6:00 ល្ងាច។ ចុះឈ្មោះសម្រាប់ការប្រជុំពីចម្ងាយតាមរយៈ៖ https://us06web.zoom.us/webinar/register/WN_veLVS545RCqGZhI6tuN2rQ ពីចម្ងាយតែប៉ុណ្ណោះ នៅថ្ងៃទី 25 ខែមករា ឆ្នាំ 2023 វេលាម៉ោង 6:00 ល្ងាច។ ចុះឈ្មោះសម្រាប់ការប្រជុំពីចម្ងាយនៅ៖ https://us06web.zoom.us/webinar/register/WN_Is2pAS_cR_uXvNhhs5r3oQ

មតិយោបល់ផ្ទាល់មាត់នឹងត្រូវទទួលយកនៅក្នុងសវនាការទាំងនេះ។

រាល់ការបញ្ចេញមតិយោបល់ជាលាយលក្ខណ៍អក្សរដែលបានដាក់ជូនពិនិត្យទាំងអស់ ត្រូវតែបញ្ចូលឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់អ្នកដែលផ្តល់មតិយោបល់។ សូមផ្ញើមតិយោបល់តាមអ៊ីម៉ែលទៅ **dep.talks@mass.gov** ហើយរាប់បញ្ចូលកម្មវិធី *Title 5 & Watershed Permit* នៅក្នុងបន្ទាត់ប្រធានបទ។ មតិយោបល់ជាលាយលក្ខណ៍អក្សរក៏អាចដាក់ជូនតាមប៉ុស្តិ៍ប្រៃសណីយ៍ ហើយត្រូវផ្ញើទៅកាន់ MassDEP ការិយាល័យធនធានទឹក (Bureau of Water Resources) – ផ្នែកគ្រប់គ្រងទឹក (Division of Watershed Management), 100 Cambridge Street, Suite 900, Boston, MA 02114, ជូនចំពោះ៖ កម្មវិធី (Title 5) និងការអនុញ្ញាតទីជម្រាល (Watershed Permit)៖

MassDEP ផ្តល់សេវាអ្នកបកប្រែផ្ទាល់មាត់/ការបកប្រែដោយសរសេរចូលប្រើប្រាស់ភាសាមួយចំនួនដល់បុគ្គលដែលមានជំនាញភាសាអង់គ្លេសដែលមានកម្រិតដោយមិនគិតថ្លៃ។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ដើម្បីចូលរួមក្នុងកិច្ចប្រជុំនេះ សេវាកម្មអាចរកបានតាមតំណភ្ជាប់ខាងក្រោម៖ https://www.mass.gov/info-details/massdep-language-translation-assistance. MassDEP មានបំណងផ្តល់សេវាបកប្រែភាសាអេស្ប៉ាញ ព័រទុយហ្គាល់ និងខាប៉េ វើឌៀន គ្រេអូល Cape Verdean Creole មួយចំនួននៅឯសវនាការសាធារណៈ។ សូមផ្តល់លិខិតជូនដំណឹងជាមុន 72 ម៉ោង ប្រសិនបើបានស្នើសុំសេវាកម្មបកប្រែភាសាបន្ថែម។

ព័ត៌មាននេះ អាចមានជាទម្រង់ដែលមានជម្រើសតាមការស្នើសុំ។

តាមបទបញ្ជារបស់ក្រសួងការពារបរិស្ថាន

Martin Suuberg, អ្នកតំណាង